ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី

លេខ.........✓.................. កកន

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
# ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី
# ឆ្នាំ២០២៥-២០៣០

ថ្ងៃចន្ទ ១០កើត ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៦

**ក្រសួងកិច្ចការនារី** មានកិត្តិយសសូមជម្រាបជូនដល់សាធារណជនទាំងអស់មេត្តាជ្រាបថា ក្រសួងកិច្ចការនារីនឹងរៀបចំពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ "ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃចន្ទ ១០កើត ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៦ វេលាម៉ោង ៨:៣០នាទីព្រឹក នៅសណ្ឋាគារ សាន់ អ៊ែន មូន និងតាមប្រព័ន្ធអនឡាញ (Zoom)។

ពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ "ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥ - ២០៣០" មានគោលបំណងផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាប្រតិបត្តិករដ៏សំខាន់ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសាធារណជនទូទៅ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់វប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងសង្គមកម្ពុជា តាមរយៈការបង្ការទប់ស្កាត់ និងធ្វើកិច្ចអន្តរាគមន៍ករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ ពិធីប្រកាសផ្សព្វផ្សាយនេះនឹងមានការអញ្ជើញចូលរួមដោយផ្ទាល់ពីថ្នាក់ដឹកនាំក្រសួងកិច្ចការនារី ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) តំណាងអង្គទូត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលពាក់ព័ន្ធ តំណាងវិស័យឯកជន សមាគមអ្នកសិល្បៈ ក្លិបអ្នកកាសែត យុវជន តំណាងសហជីព សមាគមកាយឫទ្ធិនារីកម្ពុជា និងកាកបាទក្រហមកម្ពុជា សរុបប្រមាណ ៤០០នាក់ ព្រមទាំងមានការចូលរួមតាមប្រព័ន្ធអនឡាញ (Zoom) ពីក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV-RWG) រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ មន្ទីរពាក់ព័ន្ធទាំង២៥ រាជធានី ខេត្ត ស្រុក និងការិយាល័យថ្នាក់ស្រុកពាក់ព័ន្ធ សរុបប្រមាណ១,០០០នាក់។

ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០ បានទទួលការឯកភាពពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦។

ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០ នេះ បានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រសំខាន់ៗចំនួន៤គឺ៖

យុទ្ធសាស្ត្រទី១ : ការបង្ការទប់ស្កាត់

គោលបំណងបង្កើត និងអនុវត្តយុទ្ធសាស្ត្របង្ការទប់ស្កាត់ ដើម្បីជួយណែនាំវិធានការទប់ស្កាត់ដោយផ្អែកលើភស្តុតាង និងការសម្របសម្រួលដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់។

យុទ្ធសាស្ត្រទី២ : កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ

គោលបំណងធ្វើឱ្យប្រសើរឡើងបន្ថែមទៀតក្នុងការអនុវត្តផែនការសកម្មភាពជាតិ ដោយផ្តោតលើការបន្តកសាងសមត្ថភាពរបស់ភាគីពាក់ព័ន្ធសំខាន់ៗ ស្តីពីតួនាទីនិងការទទួលខុសត្រូវក្នុងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី និងពង្រីកយន្តការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីធានាថា ជនរងគ្រោះទទួលបានសេវាពហុវិស័យ។

យុទ្ធសាស្ត្រទី៣ : ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ

គោលបំណងធ្វើវិសោធនកម្មច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដើម្បីធានាបាននូវអនុលោមភាពនិងសង្គតិភាពទៅនឹងច្បាប់ជាតិ និងអន្តរជាតិថ្មីៗ។

យុទ្ធសាស្ត្រទី៤ : ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

គោលបំណងដើម្បីធានាថា ក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃ មានភាពជាក់ស្តែង និងអាចអនុវត្តបានតាមរយៈដំណើរការរៀបចំផែនការការងារប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ ដែលបំពេញបន្ថែមដោយការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងការពិនិត្យឡើងវិញចុងក្រោយ។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកកាន់នាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី តាមរយៈទូរសព្ទលេខ ០១១២១៧ ១២៣។

ថ្ងៃសុក្រ ១៤រោច ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០២៦